long beach unified school district

OFFICE OF EQUITY, ACCESS, COLLEGE & CAREER READINESS
Volunteers in Public Schools

VIPS make a difference

Parent University

# មធ្យោបាយសំរាប់ស្ម័គ្រជួយកិច្ចការ (VIPS) នៅតាមសាលារៀនប្រចាំក្រសួងអប់រំ LBUSD

## ក្រដាសបំពេញដាក់ពាក្យ គឺតំរូវធ្វើ បួន ឆ្នាំម្តង

*ការចាត់ចែងក្រដាសបំពេញដាក់ពាក្យ VIPS នឹងចំណាយពេលប្រហែល 2 សប្តាហ៍ ឬ លើស ។ សូមអ្នកលៃលកបំពេញព័ត៌មានអោយបានត្រឹមត្រូវ រួមទាំងបង្ហាញការចុះហត្ថលេខារបស់អ្នកផង ដើម្បីជៀសវាងការពន្យារពេល ។ សូមអរគុណចំពោះការកាន់ចិត្តអត់ធ្មត់ពីអ្នក ។

**សូមចំណាំថា ក្រដាសឆ្លើយបំពេញទាំងអស់ ដែលបង្ហាញការជាប់ទោស គឺត្រូវបញ្ជាក់ជាក្រដាសភស្តុតាងមកពីតុលាការ និង គឺបភ្ជាប់វាមកជាមួយផង ។ ពេលវេលាបន្ថែមនឹងត្រូវការសំរាប់ស្រាវជ្រាវមើលជាបន្ត ។ សំរាប់សំនួរផ្សេងៗ សូមទាក់ទងអ្នកស្រី Dulnari Edirisinghe–Aga ដែលមានមុខងារគ្រប់គ្រងកម្មវិធី VIPS ប្រចាំក្រសួងអប់រំ ឌីស្រ្ទីគ តាមទូរស័ព្ទលេខ (562) 997-8307 ។**

ឆ្លើយលើក្រដាសបំពេញដាក់ពាក្យ VIPS និង បង្ហាញក្រដាសបញ្ជាក់អំពីរោគរបេង (TB) ស្របតាមការតំរូវពីច្បាប់របស់ រដ្ឋ ។ គឺបភ្ជាប់ក្រដាសបញ្ជាក់អំពីលទ្ធផលរោគរបេង និង ក្រដាស គូពី ប័ណ្ណបើកបរ ឬ អាយឌី (ID) ដែលមិនទាន់ហួស ថ្ងៃ ខែ ឆ្នាំ ទៅជាមួយក្រដាសបំពេញដាក់ពាក្យ VIPS ។

↓

នាំយកក្រដាសបំពេញដាក់ពាក្យ VIPS ដោយចុះហត្ថលេខានៅពីលើ និង ក្រដាសបញ្ជាក់អំពីលទ្ធផលរោគរបេង រួមទាំង ក្រដាស គូពី ប័ណ្ណបើកបរ ឬ អាយឌី (ID) ទៅប្រគល់ជូនអ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន ។ ក្រដាសបញ្ជាក់អំពីរោគរបេង គឺត្រូវបង្ហាញ ថ្ងៃខែបានទទួលការជោះស្បែក ថ្ងៃខែបានទទួលការពិនិត្យ (ចន្លោះពេល 48-72 ម៉ោង) និង ឈ្មោះមន្ទីរពេទ្យ ឬ គ្លីនិក ។ បើមិនចង់ជោះស្បែកទេ នៅមានមធ្យោបាយម្យ៉ាងផ្សេង ដែលអាចប្រើជំនួសបាន គឺអ្នកឆ្លើយសំនួរនៅលើក្រដាស ហៅ TB Risk Assessment Questionnaire Certificate ក្រោមការមើលខុសត្រូវពីបុគ្គលិកពេទ្យ ដែលមានសញ្ញាប័ត្រត្រឹមត្រូវ ។ សំរាប់អ្នកស្ម័គ្រចិត្តថ្មី គឺក្រដាសបញ្ជាក់ការគ្មានរោគរបេង ត្រូវបង្ហាញ ថ្ងៃ ខែ ក្នុងចំនួន 60 ថ្ងៃ នៅពេលបានបំពេញក្រដាសដាក់ពាក្យផុតទៅ និង សំរាប់លទ្ធផលពី X-ray បញ្ជាក់ការគ្មានរោគរបេង គឺត្រូវបង្ហាញ ថ្ងៃ ខែ ក្នុងចំនួន 6 ខែ នៅពេលបានបំពេញក្រដាសដាក់ពាក្យផុតទៅ ។ ប័ណ្ណអាចប្រើជាផ្លូវការបាន គឺមានដូចជា: ប័ណ្ណបើកបរ ក្នុងរដ្ឋ កាលីហ្វ័រញ៉ា ប័ណ្ណ អាយឌី (ID) ក្នុងរដ្ឋ កាលីហ្វ័រញ៉ា ប័ណ្ណទាហាន លិខិតឆ្លងដែន ឬ ប័ណ្ណផ្សេងៗ ដែលទទួលស្គាល់ជាខ្នាតអន្តរជាតិ ។

→

អ្នកស្ម័គ្រចិត្តសុំធ្វើជាគ្រូបង្ហាត់កីឡា និង អ្នកស្ម័គ្រចិត្តនៅតាមមុខងារពិសេសផ្សេងៗ គឺត្រូវបង្ហាញភស្តុតាងធ្លាប់បានធ្វើការត្រួតត្រា ឬ ត្រូវទៅធ្វើការផ្តិតមេដៃជាមួយក្រសួង DOJ និង FBI សំរាប់បំពេញស្របតាមការស្នើសុំដោយក្រសួងអប់រំ ឌីស្រ្ទីគ ។

→

**Senate Bill 792 – California Daycare Immunization Requirements for Adults:** អ្នកស្ម័គ្រចិត្តទាំងអស់ ដែលនឹងធ្វើការជាមួយសិស្ស ព្រីស្កូល នឹងត្រូវបង្ហាញការចាក់ថ្នាំបង្ការរោគកញ្ជ្រឹល ក្អកមាន់ និង **គ្រុនផ្តាសាយធ្ងន់** ហៅ *Influenza ដោយមានក្រដាសចុះហត្ថលេខាពីបុគ្គលិកមន្ទីរពេទ្យត្រឹមត្រូវភ្ជាប់មកជាមួយផង ។ (**ការចាក់ថ្នាំ *Influenza អាចទទួលលើកលែងបានស្របតាមលទ្ធផលប្រចាំឆ្នាំជារៀងរាល់ឆ្នាំ) ។**

↓

អ្នកចាត់ចែងកម្មវិធី VIPS ធ្វើការសើរើមើលអំពីភាពបំពេញត្រឹមត្រូវ និង ការបង្ហាញហត្ថលេខានៅលើក្រដាសបំពេញដាក់ពាក្យ ។ បន្ទាប់ទៅ គេ និង នាយកសាលាចុះហត្ថលេខារួមគ្នានៅលើក្រដាសនោះ ហើយផ្ញើវាទៅកាន់ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឌីស្រ្ទីគ ។

↓

ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឌីស្រ្ទីគ ត្រូវធ្វើការតាមដានបញ្ជាក់អំពីបុគ្គលទាំងអស់ ដែលបានដាក់ពាក្យសុំស្ម័គ្រ តាមរយៈបើកមើលនៅក្នុង គេហទំព័រ Megan's Law ។

→

អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀនរបស់អ្នកនឹងបានទទួលសំបុត្រយល់ព្រម ភ្ជាប់ជាមួយប័ណ្ណ VIPS ជាឈ្មោះរបស់អ្នកផង ។ បន្ទាប់ទៅ គេនឹងទាក់ទងប្រាប់អ្នក ។

↓

ឥឡូវនេះ អ្នកអាចចាប់ផ្តើមស្ម័គ្រជួយបាន ។ ដើម្បីរក្សាភាពសន្តិសុខសំរាប់សិស្ស និង មនុស្សដ៏ទៃក្នុងសាលារៀន គឺអ្នក**ត្រូវ**សរសេរកត់ឈ្មោះរាល់លើក នៅពេលអ្នកដើរចូល និង ចេញពីសាលារៀន ហើយអ្នក**ត្រូវ**ពាក់ប័ណ្ណឈ្មោះរបស់អ្នកគ្រប់ពេល ។ **ហាម**មិនអោយយកប័ណ្ណឈ្មោះរបស់អ្នកចេញក្រៅសាលារៀន លើកលែងតែនៅពេលអ្នកធ្វើដំណើរទៅជាមួយសិស្សតាមកន្លែងផ្សេងៗ និង ហាមមិនអោយមនុស្សផ្សេងខ្ចីប័ណ្ណឈ្មោះរបស់អ្នកសំរាប់ពាក់ប្រើ ។

**សូមអរគុណចំពោះការចំណាយពេលដ៏មានតំលៃ និង ការបង្ហាញថ្វីដៃដ៏ពិសេសរបស់អ្នក!**

សំរាប់សំនួរទាក់ទងការចាត់ចែងក្រដាសបំពេញដាក់ពាក្យ VIPS សូមទាក់ទងតាមទូរស័ព្ទលេខ (562) 997-8457 និង (562) 997-8307 សំរាប់សំនួរផ្សេងៗ ។